ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលការផ្តល់ប្រាក់បំណាច់មុខងារ

## ជូនកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១៨៩ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទ និង អនុក្រឹត្យលេខ ២០៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីនគរបាលជាតិ

- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកែសម្រួលប្រព័ន្ធបៀវត្ស របស់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើនប្រាក់ម្ហូបអាហារជូន កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ១៨៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលប្រាក់បៀវត្ស មូលដ្ឋានរបស់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលប្រាក់បៀវត្ស មូលដ្ឋានរបស់មន្ត្រីនគរបាលជាតិ
- បានឃើញអនុក្រឹត្យលេខ ១៧៨ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលការផ្តល់ប្រាក់ បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១.-**

ប្រាក់បំណាច់មុខងារដូចមានចែងក្នុងមាត្រា ១ និង មាត្រា ២ នៃអនុក្រឹត្យលេខ ១៧៨ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទ និងមន្ត្រី នគរបាលជាតិ ត្រូវកែប្រែប្រាក់បំណាច់មុខងារផ្តល់តាមអតីតភាព ដូចខាងក្រោម ÷

- ៥០ (ហាសិប) ភាគរយ លើមុខតំណែងជាមូលដ្ឋានពីលេខរៀង ១ (មួយ) ដល់លេខរៀង ១០ (ដប់) លើគ្រប់កម្រិតនៃអតីតភាព
- ៤៥ (សែសិបប្រាំ) ភាគរយ លើមុខតំណែងជាមូលដ្ឋានលេខរៀង ១១ (ដប់មួយ) លើគ្រប់កម្រិត នៃអតីតភាព
- ៣០ (សាមសិប) ភាគរយ លើមុខតំណែងជាមូលដ្ឋានលេខរៀង ១២ (ដប់ពីរ) លើគ្រប់កម្រិត នៃអតីតភាព
- ០ (សូន្យ) ភាគរយលើមុខតំណែងជាមូលដ្ឋានពីលេខរៀង ១៣ (ដប់បី) ដល់លេខរៀង ១៦ (ដប់ប្រាំមួយ) លើគ្រប់កម្រិតនៃអតីតភាព ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ។

**មាត្រា ៣-**

អនុក្រឹត្យនេះត្រូវចូលជាធរមានចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ